

នីតាជាសិស្សពូកែផ្នែកវិទ្យាសាស្ត្រ។ នៅពេលទំនេរ
នាងចូលចិត្តធ្វើសម្ភារៈផ្សេងៗ។ នាងចេះធ្វើត្រីវិស័យ។
នាងចេះធ្វើអំពូលភ្លើងភ្លឺដោយពន្លឺព្រះអាទិត្យ។




ថ្ងៃមួយមានសំឡេងលាន់ខ្លាំងនៅលើភ្នំខាងក្រោយផ្ទះ។
នីតាដើរទៅរកប្រភពសំឡេង។ នាងក៏ឃើញក្មេងប្រុសចម្លែកម្នាក់។



សួស្តី! តើឯងកំពុងធ្វើអ្វី?នីតាសួរក្មេងប្រុសចម្លែក។ ឮដូច្នេះ ក្មេងប្រុសនោះភ្ញាក់ផ្អើលយ៉ាងខ្លាំង។ គេក៏រត់ទៅពួននៅពីក្រោយដើមឈើ។ គេលបមើលនីតាពីក្រោយដើមឈើ។



ឯងឆាប់ចេញមក! តើខ្ញុំគួរឱ្យខ្លាចណាស់មែនទេ?
នីតាសួរបណ្តើរសើចបណ្តើរ។ សំឡេង «ទីត! ទីត!»
ចេញពីដៃរបស់ក្មេងប្រុសចម្លែក។ សំឡេង «ទីត! ទីត!»
កាន់តែញាប់ជាងមុន។ ក្មេងប្រុសចម្លែកក៏ចេញពីក្រោយដើមឈើ។



គេលើកដៃទៅរកព្រះអាទិត្យដូចមុន។ នីតាសួរ៖ តើឯងកំពុងធ្វើអីហ្នឹង?

សំឡេង «ទីត! ទីត!» ក៏ហាក់ស្ងាត់ឈឹង។ មួយសន្ទុះគេនិយាយ៖

ខ្ញុំកំពុងស្រូបថាមពលពីព្រះអាទិត្យ។ អូ! តើឯងមកពីណា?

នីតាសួរទាំងភ្ញាក់ផ្អើល។



ក្មេងប្រុសចម្លែកក៏រៀបរាប់៖ ខ្ញុំមកពីភពផ្សេង។ យានរបស់ខ្ញុំបានខូច
និងបាត់ដុំថាមពល។ ខ្ញុំត្រូវរកដុំនោះឱ្យឃើញ។
ដុំថាមពលអាចជួយឱ្យខ្ញុំត្រឡប់ទៅវិញបាន។



ខ្ញុំនឹងជួយរកឯង។ តើឯងឈ្មោះអ្វី? នីតាសួរ
។ក្មេងប្រុសចម្លែកគ្រវីក្បាល។ ឯងគ្មានឈ្មោះទេ មែនទេ? បើអីចឹង
ខ្ញុំហៅឯងថា «ផ្កាយបៃតង»! ក្មេងប្រុសញញឹម ហើយងក់ក្បាល។



ពួកគេនាំគ្នាដើររកដុំថាមពលជាមួយគ្នា។ តាំងពីថ្ងៃត្រង់រហូតដល់ល្ងាច។
តាំងពីថ្ងៃទីមួយ ដល់ថ្ងៃទីប្រាំ។ ប៉ុន្តែ ពួកគេរកមិនឃើញឡើយ។



ខ្ញុំនឹកអ្នកផ្ទះខ្ញុំណាស់។

ផ្កាយបតែងនិយាយទាំងទឹកមុខស្រពោន។ខ្លួនរបស់គេ

ក៏ចាប់ផ្តើមមានពន្លឺបន្តិចម្តងៗ។ ពេលនេះយប់ហើយ

ខ្ញុំក៏ជិតអស់ថាមពលដែរ។ ឯងត្រឡប់ទៅផ្ទះវិញទៅ។

ផ្កាយបតែងនិយាយ។



នៅយប់នោះ នីតាគេងមិនលក់សោះ។

នាងមើលរូបផ្កាយតូចៗបិទលើជញ្ជាំង។

នាងគិតពីពន្លឺនៅលើខ្លួនផ្កាយបតែង។ អូ!

ខ្ញុំនឹកឃើញមេរៀននោះហើយ។

ដុំថាមពលនឹងមានពន្លឺនៅពេលយប់។





ស្អែកឡើង នីតាបានយកអ្វីដែលនាងគិត ប្រាប់ផ្កាយបតែង។

ពួកគេក៏បន្តរកដុំថ្មពេលរហូតដល់យប់។

ទីបំផុតពួកយើងរកឃើញហើយ។ ផ្កាយបតែងស្រែក។

នុះគឺពន្លឺបតែងជះចេញពីចន្លោះដើមឈើ។

នីតាស្រែកទាំងសប្បាយចិត្ត។



លាហើយនីតា! កុមារីដ៏ក្លាហាន និងឆ្លាតវៃ។សង្ឃឹមថាថ្ងៃណាមួយ
ឯងនឹងទៅលេងភពរបស់ខ្ញុំ។ ខ្ញុំនឹងបង្កើតយានមួយ។
ខ្ញុំនឹងហោះទៅជួបឯងថ្ងៃ
ណាមួយមិនខាន។នីតាលើកដៃគ្រវីលាទាំងក្រៀមក្រំ។

រឿង ផ្កាយបតែង សមាជិកក្រុមហាក់កាសន៖ ញុំ គន្ធារ៉ូ (អ្នកនិពន្ធ) ចាន់ពិសី (វិចិត្រករ) សូ ប៊ុនឡុង (អ្នករចនា) រចនាប្លង់ចុងក្រោយដោយ៖ អ៊ុង គាមសោ

សូមថ្លែងអំណរគុណជាពិសេសដល់ហ៊ុយ រតនា សឿមកក្កដា ជូ ជីនិត និងក្រុមការងារ CamAnt Technology ចំពោះការជួយគាំទ្រដល់កម្មវិធីហាក់កាសនសៀវភៅអេឡិចត្រូនិច តោះអាន! ដែលបានធ្វើឡើងក្នុងទីក្រុងភ្នំពេញ កាលពីថ្ងៃទី ១៩ ខែ មិនា ឆ្នាំ ២០១៧។

© មូលនិធិអាស៊ីឆ្នាំ២០១៧។រក្សាសិទ្ធិមួយចំនួន។

ស្នាដៃនេះត្រូវបានការពារក្រោមអាជ្ញាប័ណ្ណប្រភេទ Creative Commons Attribution-NonCommercial 4.0 (http://creativecommons.org/licenses/by-nc/4.0/) ។ អ្នកអាចចម្លង (ថតចម្លង និងចែកចាយបន្តឯកសារនេះ ដោយមធ្យោបាយ ឬក្នុងទម្រង់អ្វីក៏បាន)ដោយសេរី និងធ្វើការកែសម្រួល (លាយបញ្ចូលជាមួយខ្លឹមសារផ្សេងទៀត បម្លែង និងបង្កើតជាឯកសារផ្សេងៗទៀត) លបំណងមិនមែនពាណិជ្ជកម្ម។អ្នកចេញអាជ្ញាប័ណ្ណមិនអាចដកហូតសេរីភ ដរាបណាអ្នកគោរពទៅតាមលក្ខខណ្ឌនៃអាជ្ញាប័ណ្ណដូចខាងក្រោម៖ សេចក្តីថ្លែងអំណរគុណ-អ្នកត្រូវសរសេរពីប្រភពឯកសារឲ្យបានសមស្រប បង្ហាញពីតំណភ្ជាប់ទៅកាន់អាជ្ញាប័ណ្ណ និងបញ្ជាក់ពីការផ្លាស់ប្តូរខ្លឹមសារ ប្រសិនបើមាន។

អ្នកអាចធ្វើបែបនេះ តាមវិធីណាក៏បានដែរសមស្រប ប៉ុន្តែពុំមានន័យថា អ្នកផ្តល់អាជ្ញាប័ណ្ណគាំទ្រដល់អ្នក ឬដល់ការប្រើប្រាស់របស់អ្នកនោះទេ។
មិនមែនលក្ខណៈពាណិជ្ជកម្ម-អ្នកមិនអាចប្រើប្រាស់ឯកសារនេះ សម្រាប់គោលបំណងពាណិជ្ជកម្មឡើយ។
Green Star Hackathon team: Prum Kunthearo (Writer), Chan Pisey (Illustrator), So Bunlong (Graphic Designer) Final layout by: Ong Keamesa
Special thanks to Huy Rattana, Soeurm Kakada, Chou Chinith, and the CamAnt Technology team for their help with the Let’s Read! E-book Hackathon, which took place in Phnom Penh on 19 March 2017.
© The Asia Foundation, 2017. Some rights reserved. This work is licensed under a Creative Commons Attribution-NonCommercial 4.0 Licence (http://creativecommons.org/licenses/by-nc/4.0/). You are free to share (copy and redistribute the material in any medium or format) and adapt (remix, transform, and build upon the material) this work for any non-commerical purpose. The licensor cannot revoke these freedoms as long as you follow the following license terms:
Attribution- You must give appropriate credit, provide a link to the license, and indicate if changes were made. You may

do so in any reasonable manner, but not in any way that suggests the licensor endorses you or your use.

NonCommercial — You may not use the material for commercial purposes.

តោះ អាន!

The Asia Foundation

Generously Supported By

Smart